ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងបង្កាត់ភ្ញាស់កូនត្រីឆ្ពិន
# ក្នុងស្រះ



គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ អេ.អ.ឌី.ប៊ី
ឆ្នាំ២០២២

# មាតិកា


**១-សេចក្តីសង្ខេបនៃគម្រោង** ....................................................................................2

**២-លក្ខណៈជីវសាស្ត្ររបស់ត្រីឆ្ពិន** ....................................................................................3

**៣-វិធីសាស្ត្របង្កាត់ភ្ញាស់កូនត្រីឆ្ពិន** ....................................................................................4

៣-១-ការជ្រើសរើសមេពូជ ....................................................................................4

៣-២-ការចាក់អ័រម៉ូនរំញោច ....................................................................................4

៣-៣-ការបង្កាត់ ....................................................................................5

៣-៤-ការភ្ញាស់ពង ....................................................................................5

៣-៥-ការដាក់កូនត្រីទើបនឹងញាស់ចូលទៅក្នុងស្រះបំប៉ន ....................................................................................5

៣-៦-ការរៀបចំស្រះបំប៉នកូនត្រីទើបនឹងញាស់ ....................................................................................5

៣-៧-ចំណីសម្រាប់បំប៉នកូនត្រី ....................................................................................5

៣-៨-ការប្រមូលផល ....................................................................................5

**៤-គម្រោងចំណាយលើការបង្កាត់ភ្ញាស់កូនត្រីឆ្ពិន** ....................................................................................6

៤-១-ការវិភាគលើការចំណាយសម្រាប់ការចាប់ផ្តើមអាជីវកម្មដំបូង ....................................................................................6

៤-២-ការវិភាគសេដ្ឋកិច្ចលើការចិញ្ចឹម១វគ្គ ....................................................................................7

៤-៣-ការវិភាគសេដ្ឋកិច្ចដោយផ្អែកលើនិន្នាការតម្លៃលក់កូនត្រី ....................................................................................9

**៥-ហានិភ័យ** ....................................................................................9

**៦-សេចក្តីសន្និដ្ឋាន** ....................................................................................10

## ១-សេចក្ដីសង្ខេបនៃគម្រោងបង្កាត់ភ្ញាស់កូនត្រីឆ្ពិន

-កសិដ្ឋានបង្កាត់ភ្ញាស់ ÷ សង្កាត់អូរម៉ាល់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

-ចំនួន និងទំហំស្រះ ÷ ស្រះផ្សាំកូនត្រីចំនួន ០២ មានទំហំ ៣០ម x ១៥ម x ២ម

-ចំនួនត្រីមេពូជ ÷ ត្រីឈ្មោល ០៣គ.ក និងត្រីញី ០៥គ.ក

-ប្រភពត្រីមេពូជ ÷ ជាត្រីសាច់ក្នុងកសិដ្ឋាន
(ប្រសិនទិញពីខាងក្រៅតម្លៃ ២០,០០០រៀល/គ.ក)

-ចំនួនវគ្គបង្កាត់ភ្ញាស់/ឆ្នាំ ÷ ៤-៥ដង/ឆ្នាំ

-រដូវកាលបង្កាត់ភ្ញាស់ ÷ ចន្លោះខែ៥ដល់ខែ៩ និងជាទូទៅអាចបន្តពូជបានពេញ១ឆ្នាំ
លើកលែងតែ ខែ១១ និងខែ១២ (ចុងឆ្នាំ)។

-រយៈពេលផលិតកូនត្រី ÷ ២.៥-៣ខែ/វគ្គ

-អត្រាបាត់បង់ ÷ ចន្លោះពី ៥-១០% អាស្រ័យលើការថែទាំ

-ទិន្នផលផលិតបាន ÷ កូនត្រីពូជចំនួន ១០០,០០០ក្បាល

-ទីផ្សារ ÷ អតិថិជនក្នុងខេត្ត និងក្រៅខេត្ត

-តម្លៃលក់កូនត្រី ÷ ចន្លោះពី ៨០-១២០រៀល/ក្បាល អាស្រ័យលើទំហំកូនត្រី

-តម្រូវការទុន ÷ សម្រាប់ការចាប់ផ្ដើមអាជីវកម្មដំបូង ដោយរៀបប្រព័ន្ធបង្កាត់ភ្ញាស់
ចល័ត ត្រូវចំណាយដើមទុនចំនួន ÷ **១៤,១៣៨,៥០០រៀល**
(ករណីមានដីខ្លួនឯងសម្រាប់ជីកស្រះផ្សាំកូនត្រី)។

| ទុនវិនិយោគសម្រាប់ជីកស្រះ សម្ភារៈ និងប្រព័ន្ធបង្កាត់ភ្ញាស់ | ទុនសម្រាប់ការបង្កាត់ភ្ញាស់ និងការវេចខ្ចប់ | ទឹកប្រាក់សរុប |
|---|---|---|
| **១០,២០៨,០០០រៀល** | **៣,៩៣០,៥០០រៀល** | **១៤,១៣៨,៥០០រៀល** |

-ការវិភាគសេដ្ឋកិច្ចសម្រាប់ការបង្កាត់ភ្ញាស់កូនត្រីឆ្ពិនចំនួន ១០០,០០០កូន ក្នុងរយៈពេល ២.៥ ខែ ទៅ ៣ខែ (ក្នុង១វគ្គ) ក្រោយកាត់រំលស់លើការចំណាយថេរ និងការចំណាយលើការផលិត÷

| ចំណាយសរុប | ចំណូលសរុប | ចំណេញសរុប |
|---|---|---|
| **៤,៣៧៣,៧២២រៀល** | **១០,០០០,០០០រៀល** | **៥,៦២៦,២៧៨រៀល** |

## ២-លក្ខណៈជីវសាស្ត្ររបស់ត្រីឆ្ពិន

ត្រីឆ្ពិនជាប្រភេទត្រីក្នុងស្រុក រស់នៅតាមតំបន់ជាច្រើនក្នុងទឹកសាប (ដងទន្លេ បឹង ស្ទឹង ព្រែក ប្រឡាយ ស្រះ និងក្នុងស្រែ) ជាប្រភេទត្រីដែលប្រជាពលរដ្ឋនិយមចូលចិត្តបរិភោគ និងងាយស្រួលចិញ្ចឹម ជាពិសេសកសិករនៅតាមជនបទនិយមចិញ្ចឹម និងផលិតកូនត្រីបានជាលក្ខណៈគ្រួសារទៀតផង។



**ឈ្មោះជាភាសាខ្មែរ÷** ត្រីឆ្ពិន

**ឈ្មោះវិទ្យាសាស្ត្រ÷** Barboides gonionotus

**ឈ្មោះជាភាសាអង់គ្លេស÷** Silver barb

ត្រីឆ្ពិន មានដងខ្លួនទ្រវែង ផ្ទៃសងខាងនៃដងខ្លួនមានលក្ខណៈសំប៉ែត។ នៅពេលពេញវ័យដងខ្លួនត្រីញីមានភាពផតចូលខ្លាំងជាងត្រីឈ្មោល។ ត្រីឆ្ពិនមានពណ៌ស្រដៀងប្រាក់គ្របដណ្តប់លើដងខ្លួនទាំងមូល មានក្បាលតូច ព្រុយខ្នងវែង ទ្រនុងឆ្អឹងខ្នងក្រាស់ ព្រុយកន្ទុយបែកព្រែកជាជំពាម គែមស្រកាមានភាពក្រម៉ៅ ព្រុយពោះ និងព្រុយគូទមានភាពលឿងស្រាល។ ត្រីឆ្ពិន មិនមានក្រពះទេ ប៉ុន្តែវាមានពោះវៀនវែងជាង ២ ទៅ ៣ដងនៃប្រវែងដងខ្លួន។ វាអាចរស់នៅទាំងបីស្រទាប់ទឹក (លើ កណ្តាល និងបាត) វាចូលចិត្តរស់នៅទឹកស្អាត និងសម្បូរអុកស៊ីសែន។

- **មជ្ឈដ្ឋានទឹកសមស្របសម្រាប់ការលូតលាស់ និងធំធាត់របស់ត្រីឆ្ពិន÷**
  - -សីតុណ្ហភាពសមស្រប ÷ ២៥-៣០អង្សាសេ
  - -កម្រិតអុកស៊ីសែនរលាយក្នុងទឹក÷ ៣-៥មីលីក្រាម/លីត្រទឹក
  - -កំហាប់ pH ចន្លោះពី ÷ ៦-៨
  - -កម្រិតថ្លានៃទឹក ÷ ៣០-៤៥សង់ទីម៉ែត្រ
- **ចរឹកស៊ីចំណី÷** ជាប្រភេទត្រីស៊ីចម្រុះ ដូចជា ស្លែ ត្រកួន ចកបាយទា ស្លឹកកន្ទំថេត ជន្ទល់ភ្នំ សារាយ កន្ទក់ ចុងអង្ករ សណ្តែក ពោត ស្រូវបណ្តុះ កណ្តៀរ សំណល់ផ្ទះបាយ លាមកគោ ក្របី ជ្រូក មាន់ ។ល។ សម្រាប់ការចិញ្ចឹមបែបប្រពលវប្បកម្ម ចំណីសម្រេចពីក្រុមហ៊ុន (ចំណីគ្រាប់) គឺជាជម្រើសដ៏ល្អបំផុតដើម្បីជំរុញការលូតលាស់ ទទួលបានទិន្នផលខ្ពស់ និងស្របតាមតម្រូវការទីផ្សារ។ ប៉ុន្តែចំណីធម្មជាតិខាងលើនៅតែប្រើប្រាស់សម្រាប់បំពេញបន្ថែម ដើម្បីចូលរួមកាត់បន្ថយការចំណាយថ្លៃដើមផលិតកម្ម។
- **ការបន្តពូជ÷** ត្រីឆ្ពិនអាចបន្តពូជចាប់ពីអាយុ ០.៨-១ឆ្នាំឡើង នៅចន្លោះខែ៥ដល់ខែ៩ និងជាទូទៅអាចបន្តពូជបានពេញ១ឆ្នាំ លើកលែងតែ ខែ១១ និង១២ចុងឆ្នាំ។ ត្រីឆ្ពិនអាចបន្តពូជបានពី ៤-៥ ដង/ឆ្នាំ និងជាប្រភេទត្រីមានពងបណ្តែតតាមចរន្តទឹក។ ដូចនេះពេលបង្កកំណើតវាត្រូវបន្លាស់ទីទៅ

រកកន្លែងមានចរន្តទឹកវិលឬនៅពេលមានភ្លៀងធ្លាក់ខ្លាំងឬពេលបូមទឹកបញ្ចូលស្រះនៅពេលយប់។ ត្រីឈ្មោលមានព្រុយទ្រូងគ្រាត និងត្រីញីមានព្រុយទ្រូងរលោង។

- **ការលូតលាស់÷** ត្រីញីលូតលាស់ និងធំធាត់លឿនជាងត្រីឈ្មោល។ ចិញ្ចឹមរយៈពេល ០១ឆ្នាំ ត្រីអាចមានទម្ងន់ចន្លោះពី ០.៣ ទៅ ០.៥គ.ក/ក្បាល និងចិញ្ចឹមរយៈពេល០២ឆ្នាំអាចមានទម្ងន់ចន្លោះពី ១.៥ ទៅ ១.៩គ.ក/ក្បាល។

## ៣-វិធីសាស្ត្របង្កាត់ភ្ញាស់កូនត្រីឆ្តិន

**៣-១-ការជ្រើសរើសត្រីមេពូជ÷** គឺជាការងារសំខាន់បំផុតសម្រាប់ការបង្កាត់ភ្ញាស់កូនត្រីឆ្តិនដែលកសិករត្រូវយកចិត្តទុកដាក់និងមានភាពច្បាស់លាស់។ ត្រីមេពូជគួរជ្រើសចេញពីស្រះចិញ្ចឹមត្រីសាច់ក្នុងកសិដ្ឋានឬនាំចូលដោយដឹងពីប្រភពច្បាស់លាស់ និងផ្តោតលើលក្ខខណ្ឌដូចខាងក្រោម÷

| | | |
|---|---|---|
| -អាយុត្រី | ÷ | ចាប់ពី ០១ឆ្នាំឡើង |
| -ទម្ងន់ត្រី | ÷ | ត្រីញីចាប់ពី ៧០០ក្រាម និងត្រីឈ្មោលចាប់ពី ៥០០ក្រាមឡើងទៅ |
| -ទំហំត្រី និងរូបរាង | ÷ | ប្រហាក់ប្រហែលគ្នា មានសុខភាពល្អ រហ័សរហួន មាំមួន ពណ៌ស្រស់ថ្លា គ្មានរបួសស្នាមឬដំបៅ និងគ្មានជម្ងឺ។ |

**៣-២-ការចាក់អ័កម៉ូនរំញោច÷** ដើម្បីបង្កាត់ភ្ញាស់កូនត្រីឆ្តិនបាន ១០០,០០០កូន ត្រូវការត្រីមេពូជចន្លោះពី ៦-៨គ.ក ដោយប្រើកម្រិតត្រីញី ៤-៥គ.ក និងត្រីឈ្មោល៣-៤គ.ក។ ដំណើរការបង្កាត់ត្រូវប្រើថ្នាំអ័រម៉ូនប្រភេទ ស៊ុបព្រីហ្វាក់ (Suprefact) និងឱសថម៉ូទីល្យូម (Motilium) លើត្រីមេពូជដើម្បីរំញោចក្រពេញបន្តពូជឱ្យឆាប់ពេញវ័យ និងត្រីអាចបង្កាត់តាមពេលកំណត់។

អ័កម៉ូន ស៊ុបព្រីហ្វាក់ Suprefact (GnRh)







ឱសថម៉ូទីល្យូម Motilium (Domperidone)




ការរៀបចំអ័កម៉ូនសម្រាប់ចាក់ត្រីមេពូជ

**៣-៣-ការបង្កាត់÷** ក្រោយចាក់អ័កម៉ូនរួចរាល់ ត្រីមេពូជត្រូវបានដាក់ទៅក្នុងធុងជំរបង្កាត់ (ធុងជំរ ចំណុះ ១,០០០លីត្រ) ដែលមានទឹកជម្រៅ ០.២-០.៣សង់ទីម៉ែត្រ។ ក្នុងករណីសីតុណ្ហភាពទឹកពី ២៨-៣០ អង្សាសេ ត្រីឆ្កិននឹងទម្លាក់ពងក្រោយពេលចាក់អ័កម៉ូនពី ៤-៦ម៉ោង។

**៣-៤-ការភ្ញាស់ពង÷** ការភ្ញាស់ពងត្រីចាំបាច់ត្រូវការឱ្យមានបរិមាណអុកស៊ីសែនរលាយក្នុងទឹកគ្រប់គ្រាន់ ទើបពងត្រីមានអត្រាញាស់ខ្ពស់។ ដូចនេះ កសិករត្រូវរៀបចំប្រព័ន្ធអុកស៊ីសែនក្នុងអាង/ធុងភ្ញាស់ ដើម្បីបង្កើនកម្រិតអុកស៊ីសែន និងជំរុញចលនាទឹកវិល។ រយៈពេលពងត្រីឆ្កិនញាស់ចាប់ពីពេលផ្សំកំណើតក្នុងកម្រិតសីតុណ្ហភាពទឹកពី ២៨-៣០អង្សាសេ មានរយៈពេលពី ៩-១១ម៉ោង។

**៣-៥-ការដាក់កូនត្រីទើបនឹងញាស់ចូលទៅក្នុងស្រះបំប៉ន÷** ពេលវេលាសមស្របសម្រាប់ដាក់កូនត្រីឆ្កិនទៅក្នុងស្រះបំប៉ន គឺបន្ទាប់ពីកូនត្រីមានអាយុពី ៣-៤ថ្ងៃក្រោយពេលញាស់ ពីព្រោះពេលនេះ កូនត្រីអស់អាហារបម្រុង (អាហារបម្រុងប្រើបានតែ ២-២.៥ថ្ងៃ) កូនត្រីមានភាពធនទៅនឹងការជងជួស និងមានលទ្ធភាពគេចពីពពួកសត្វចង្រៃដែលមាននៅក្នុងស្រះបាន។

**៣-៦-ការរៀបចំស្រះបំប៉នកូនត្រីទើបនឹងញាស់÷** ស្រះបំប៉នកូនត្រីម្សៅមិនត្រូវដាក់ជីលាមកសត្វឡើយ ដើម្បីជៀសវាងកើតមានសត្វល្អិតដែលនឹងស៊ីកូនត្រីម្សៅ។ ត្រូវរៀបចំស្រះចន្លោះពី ២-៣ថ្ងៃមុនដាក់កូនត្រីម្សៅ នៅពេលនោះទឹកក្នុងស្រះមិនត្រូវការមានពណ៌បៃតងឡើយ ពីព្រោះពេលនោះពពួកប្លង់តុងតូចៗ (រ៉ូទីហ្វ៊ែរ) រុក្ខជាតិប្លង់តុង និងបាក់តេរីតូចៗ គឺជាចំណីល្អដំបូងបំផុតរបស់កូនត្រីម្សៅ។

**៣-៧-ចំណីសម្រាប់បំប៉នកូនត្រី÷** ក្រៅពីចំណីធម្មជាតិ ត្រូវផ្តល់បន្ថែមនូវចំណីសម្រេចក្រុមហ៊ុនដែលមានប្រូតេអ៊ីន ៤០% សម្រាប់ភាគរយចំណី ៣-៥% នៃទម្ងន់ត្រីសរុបក្នុងស្រះ (ផ្តល់៣ដង/ថ្ងៃ)។

**៣-៨-ការប្រមូលផល÷** ក្រោយពីចិញ្ចឹមបំប៉ន ២.៥-៣ខែ កូនត្រីអាចមានទំហំពី ៨-១២លី/កូន ឬ ១.៥-៣ក្រាម/កូន និងអាចប្រមូលផលបាន ដោយប្រើអួនសាច់ទន់ មិនទាក់នឹងព្រុយត្រី និងកាត់បន្ថយការកកិតជងខ្លួនត្រី។












**ការរែងជ្រើសរើសកូនត្រីពូជ ទៅតាមទំហំដែលអតិថិជនបញ្ជាទិញ និងការវេចខ្ចប់កូនត្រីពូជ**

## ៤-គម្រោងចំណាយលើការបង្កាត់ភ្ញាស់កូនត្រីឆ្ពិន៖

គម្រោងបង្កាត់ភ្ញាស់កូនត្រីឆ្ពិននេះ បានសិក្សានៅកសិដ្ឋាន ដែលកំពុងដំណើរការបង្កាត់ភ្ញាស់កូនត្រីឆ្ពិន និងចិញ្ចឹមត្រីឆ្ពិនសាច់ស្ថិតនៅសង្កាត់អូរម៉ាល់ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

- ប្រព័ន្ធបង្កាត់ភ្ញាស់ចល័ត ÷ ប្រើធុងជ័រជ្រុងចំនួន០១ មានចំណុះ ១,០០០លីត្រ និងធុងជ័រមូលចំនួន៨ ចំណុះ ២០០លីត្រ)។
- ចំនួនត្រីមេពូជ ÷ ត្រីមេ ៥គ.ក និងត្រីឈ្មោល ៣គ.ក
- ចំណីផ្តល់ឱ្យកូនត្រីស៊ី ÷ ចំណីក្រុមហ៊ុនដែលមានកម្រិតប្រូតេអ៊ីន ៤0%
- រយៈពេលផលិត ÷ ២.៥-៣ខែ/វគ្គ
- ទុនចំណាយសរុប ÷ ១៤,១៣៨,៥០០រៀល

### ៤-១-ការវិភាគលើការចំណាយ÷ *(ការចាប់ផ្តើមអាជីវកម្មដំបូង)*

| លរ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃរាយ (រៀល) | តម្លៃសរុប(រៀល) |
|---|---|---|---|---|---|
| **ចំណាយសរុប ក+ខ** | | | | | **14,138,500** |
| **ក-ការចំណាយប្រែប្រួល (ក១ + ក២)** | | | | | **3,930,500** |
| **ក១-ចំណាយសម្រាប់ផលិតកម្ម** | | | | | **3,805,500** |
| 1 | កំបោរស (រៀបចំស្រះបំប៉នកូនត្រីម្សៅ) | គ.ក | 50 | 2,000 | 100,000 |
| 2 | មេបាពូជ( ឈ្មោល- ញី) | គ.ក | 8 | 20,000 | 160,000 |
| 3 | អ័កម៉ូន (Suprefact + Motilium) | វគ្គ | 1 | 5,000 | 5,000 |
| 4 | សម្ភារៈ( សេរាំង, ម្ជុល, ទឹកស៊ីរ៉ូម) | វគ្គ | 1 | 15,000 | 15,000 |
| 5 | ជី UREA | គ.ក | 3 | 3,500 | 10,500 |
| 6 | ជី DAP | គ.ក | 2 | 4,000 | 8,000 |
| 7 | ចំណីសម្រេចរោងចក្រ ប្រូតេអ៊ីន៤0% | គ.ក | 45 | 6,000 | 270,000 |
| 8 | ប្រេងឥន្ធៈ( សាំង/ ម៉ាស៊ូត) | លីត្រ | 30 | 6,300 | 189,000 |
| 9 | អគ្គិសនី/ វគ្គ | វគ្គ | 1 | 48,000 | 48,000 |
| 10 | កម្លាំងពលកម្ម/ វគ្គ | វគ្គ | 1 | 3,000,000 | 3,000,000 |
| **ក២-ចំណាយសម្រាប់ប្រតិបត្តិការលក់** | | | | | **125,000** |
| 1 | ថង់ប្លាស្ទិច( វេចខ្ចប់) | គ.ក | 5 | 20,000 | 100,000 |
| 2 | កៅស៊ូកង | គ.ក | 1 | 5,000 | 5,000 |
| 3 | ខ្យល់អុកស៊ីសែន | កំប្លេ | 1 | 20,000 | 20,000 |
| **ខ-ចំណាយមិនប្រែប្រួល/ ថេរ** | | | | | **10,208,000** |

| | | | | | |
|---|---|---|---|---|---|
| 1 | ស្រះបំប៉ន (៣០ម x១៥ម x២ម) | ស្រះ | 2 | 1,800,000 | 3,600,000 |
| 2 | ធុងជ័រសម្រាប់បង្កាត់ (ចំណុះ១០០០លីត្រ) | ធុង | 1 | 400,000 | 400,000 |
| 3 | ធុងជ័រសម្រាប់ភ្ញាស់ពង (ចំណុះ២០០លីត្រ) | ធុង | 8 | 80,000 | 640,000 |
| 4 | ប្រព័ន្ធទុយោសម្រាប់ធុងបង្កាត់ភ្ញាស់ | កំប្លេ | 1 | 80,000 | 80,000 |
| 5 | ម៉ូទ័រខ្យល់ | គ្រឿង | 1 | 320,000 | 320,000 |
| 6 | ធុងអុកស៊ីសែន + នាឡិកា | កំប្លេ | 1 | 600,000 | 600,000 |
| 7 | សម្ភារៈសម្រាប់ប្រព័ន្ធខ្យល់ | កំប្លេ | 1 | 100,000 | 100,000 |
| 8 | កញ្ច្រែងរែងកូនត្រី | កញ្ច្រែង | 3 | 40,000 | 120,000 |
| 9 | អួនអូសកូនត្រីពូជ | វង់ | 1 | 350,000 | 350,000 |
| 10 | ហាប៉ា (២មx៤មx១ម) | វង់ | 5 | 20,000 | 100,000 |
| 11 | ម៉ាស៊ីនបូមទឹក(ម៉ាស៊ូត) | គ្រឿង | 1 | 2,800,000 | 2,800,000 |
| 12 | ម៉ូទ័របូមទឹក | គ្រឿង | 1 | 200,000 | 200,000 |
| 13 | ទុយោបូមទឹកសម្រាប់ស្រះផ្សាំកូនត្រី (៨ហ៊ុន) | ដើម | 20 | 30,000 | 600,000 |
| 14 | ស្បៃហ៊ុំស្រះបំប៉នកូនត្រីម្សៅ | ដុំ | 10 | 25,000 | 250,000 |
| 15 | បង្គោលឫស្សី | បាច់ | 6 | 7,000 | 42,000 |
| 16 | ខ្សែចំណង | គ.ក | 2 | 3,000 | 6,000 |

## ៤-២-ការវិភាគសេដ្ឋកិច្ចក្នុងការចិញ្ចឹម១វគ្គ÷

| លរ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃរាយ (រៀល) | ចំនួនវដ្តវិលោះ | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|---|
| **ចំណូលពីការលក់កូនត្រី** | | | | | | |
| 1 | ចំណូលពីការលក់កូនត្រី | ក្បាល | 100,000 | 100 | | **10,000,000** |
| **ចំណាយសរុប ក+ខ** | | | | | | **4,373,722** |
| **ក-ការចំណាយប្រែប្រួល (ក១ + ក២)** | | | | | | **3,930,500** |
| **ក១-ចំណាយសម្រាប់ផលិតកម្ម** | | | | | | **3,805,500** |
| 1 | កំបោរស (ស្រះបំប៉នកូនត្រីម្សៅ) | គ.ក | 50 | 2,000 | | 100,000 |
| 2 | មេបាពូជ(ឈ្មោល-ញី) | គ.ក | 8 | 20,000 | | 160,000 |
| 3 | អ័កម៉ូន (Suprefact + Motilium) | វគ្គ | 1 | 5,000 | | 5,000 |
| 4 | សម្ភារៈ(សេរាំង,ម្ជុល,ទឹកស៊ីរ៉ូម) | វគ្គ | 1 | 15,000 | | 15,000 |
| 5 | ជី UREA | គ.ក | 3 | 3,500 | | 10,500 |
| 6 | ជី DAP | គ.ក | 2 | 4,000 | | 8,000 |
| 7 | ចំណីសម្រេច(ប្រូតេអ៊ីន៤០%) | គ.ក | 45 | 6,000 | | 270,000 |

| | | | | | | |
|---|---|---|---|---|---|---|
| 8 | ប្រេងឥន្ទនៈ(សាំង/ម៉ាស៊ូត) | លីត្រ | 30 | 6,300 | | 189,000 |
| 9 | អគ្គីសនី/វគ្គ | វគ្គ | 1 | 48,000 | | 48,000 |
| 10 | កម្លាំងពលកម្ម/វគ្គ | វគ្គ | 1 | 3,000,000 | | 3,000,000 |
| **ក២-ចំណាយសម្រាប់ប្រតិបត្តិការលក់** | | | | | | **125,000** |
| 1 | ថង់ប្លាស្ទិច (វេចខ្ចប់) | គ.ក | 5 | 20,000 | | 100,000 |
| 2 | កៅស៊ូកង | គ.ក | 1 | 5,000 | | 5,000 |
| 3 | ខ្យល់អុកស៊ីសែន | ធុង | 1 | 20,000 | | 20,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **443,222** |
| 1 | ស្រះបំប៉ន (៣០ម x១៥ម x២ម) | ស្រះ | 2 | 1,800,000 | 60 | 60,000 |
| 2 | ធុងជ័រសម្រាប់បង្កាត់ (ចំណុះ១០០០លីត្រ) | ធុង | 1 | 400,000 | 15 | 26,667 |
| 3 | ធុងជ័រសម្រាប់ភ្ញាស់ពង(ចំណុះ២០០លីត្រ) | ធុង | 8 | 80,000 | 15 | 42,667 |
| 4 | ប្រព័ន្ធទុយោសម្រាប់ធុងបង្កាត់ភ្ញាស់ | កំប្លេ | 1 | 80,000 | 30 | 2,667 |
| 5 | ម៉ូទ័រខ្យល់ | គ្រឿង | 1 | 320,000 | 15 | 21,333 |
| 6 | ធុងអុកស៊ីសែន (អុកស៊ីសែន+ នាឡិកា) | កំប្លេ | 1 | 600,000 | 30 | 20,000 |
| 7 | ប្រព័ន្ធ/ សម្ភារៈសម្រាប់ខ្យល់ | កំប្លេ | 1 | 100,000 | 9 | 11,111 |
| 8 | កញ្ច្រែងរែងកូនត្រី | កញ្ច្រែង | 3 | 40,000 | 15 | 8,000 |
| 9 | អួនអូសកូនត្រីពូជ | វង់ | 1 | 350,000 | 15 | 23,333 |
| 10 | ហាប៉ា (២មx៤មx១ម) | វង់ | 5 | 20,000 | 9 | 11,111 |
| 11 | ម៉ាស៊ីនបូមទឹក(ម៉ាស៊ូត) | គ្រឿង | 1 | 2,800,000 | 21 | 133,333 |
| 12 | ម៉ូទ័របូមទឹក | គ្រឿង | 1 | 200,000 | 15 | 13,333 |
| 13 | ទុយោបូមទឹកសម្រាប់ស្រះផ្សាំកូន(៨ហ៊ុន) | ដើម | 20 | 30,000 | 30 | 20,000 |
| 14 | ស្បៃហ៊ុំស្រះបំប៉នកូនត្រីម្សៅ | ដុំ | 10 | 25,000 | 6 | 41,667 |
| 15 | បង្គោលឫស្សី | បាច់ | 6 | 7,000 | 6 | 7,000 |
| 16 | ខ្សែចំណង | គ.ក | 2 | 3,000 | 6 | 1,000 |
| **ចំណោញសរុប** | | | | | | **5,626,278** |
| ចំណាយថ្លៃដើមក្នុងការបង្កាត់ភ្ញាស់កូនត្រី ក្នុង១ក្បាល | | | | | | **43.74** |
| ចំណេញពីការផលិតកូនត្រី ១ក្បាល | | | | | | **56.26** |

### ៤-៣-ការវិភាគសេដ្ឋកិច្ចដោយផ្អែកលើនិន្នាការតម្លៃលក់÷

-ទិសដៅបង្កាត់ភ្ញាស់កូនត្រីឆ្ពិន ÷ ១០០,០០០កូន

-តម្លៃកូនត្រីលក់ចេញទាបបំផុត ÷ ៨០រៀល/កូន

-តម្លៃខ្ពស់បំផុតរហូតដល់ ÷ ១២០រៀល/កូន

| ទិន្នផលទទួលបាន(ក្បាល) | តម្លៃកូនត្រីលក់ចេញ(រៀល) | ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | ចំណេញ (រៀល) | កំណត់សម្គាល់អំពីទិន្នផល |
|---|---|---|---|---|---|
| 100,000 | 80 | 8,000,000 | 5,626,278 | 2,373,722 | ករណីផលិតកម្មសម្រេចបានតាមផែនការកំណត់ |
| | 100 | 10,000,000 | 5,626,278 | 4,373,722 | |
| | 120 | 12,000,000 | 5,626,278 | 6,373,722 | |
| 80,000 | 80 | 6,400,000 | 5,626,278 | 773,722 | ករណីកូនត្រីបាត់បង់២០% |
| | 100 | 8,000,000 | 5,626,278 | 2,373,722 | |
| | 120 | 9,600,000 | 5,626,278 | 3,973,722 | |
| 50,000 | 80 | 4,000,000 | 5,626,278 | (1,626,278) | ករណីកូនត្រីបាត់បង់៥០% |
| | 100 | 5,000,000 | 5,626,278 | (626,278) | |
| | 120 | 6,000,000 | 5,626,278 | 373,722 | |

## ៥-ហានិភ័យ÷

តាមរយៈចុះសិក្សាជាមួយម្ចាស់កសិដ្ឋានបង្កាត់ភ្ញាស់កូនត្រីឆ្ពិនផ្ទាល់នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង មានហានិភ័យមួយចំនួនដែលអាចកើតឡើងជាយថាហេតុលើដំណើរការបង្កាត់ភ្ញាស់កូនត្រីឆ្ពិន នាំឱ្យប៉ះពាល់ដល់ផលិតកម្មភ្ញាស់កូនត្រីរបស់កសិដ្ឋាន។ កសិករគួររៀបចំផែនការជាក់លាក់ ដើម្បីកាត់បន្ថយ និងគ្រប់គ្រងហានិភ័យបានប្រកបដោយប្រសិទ្ធភាពខ្ពស់។

ហានិភ័យចម្បងៗក្នុងការបង្កាត់ភ្ញាស់កូនត្រីឆ្ពិនមានដូចខាងក្រោម÷

| ល.រ | ប្រភេទហានិភ័យ | ហានិភ័យ | វិធានការ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | មេពូជត្រីមិនល្អ ផលិតកូនត្រីមិនល្អ ធំធាត់យឺត ធំមិនស្មើគ្នា អត្រារស់ទាប។ | - ជ្រើសរើសត្រីមេពូជក្នុងកសិដ្ឋានដែលបានថែបំប៉នល្អ<br>- ត្រីមេពូជញី-ឈ្មោលមានទំហំប្រហាក់ប្រហែលគ្នា<br>- ទិញត្រីមេពូជពីខាងក្រៅបន្ថែម ដើម្បីជៀសវាងត្រីមេពូជជាន់ឈាម។ |
| | | តម្លៃធាតុចូលឡើងថ្លៃខ្ពស់នាំឱ្យថ្លៃដើមផលិតខ្ពស់។ | - ពង្រឹងបច្ចេកទេសបង្កាត់ភ្ញាស់ថ្មីៗបន្ថែម ដើម្បីកង្កើនប្រសិទ្ធិភាពផលិតកម្ម កាត់បន្ថយថ្លៃដើមផលិត។<br>- សិក្សាអំពីវិធីសាស្ត្រឬបច្ចេកទេសក្នុងការផលិតចំណីកែច្នៃរួមផ្សំចេញពីវត្ថុធាតុដើមក្នុងតំបន់ និងងាយរកបាន។ |

| | | | |
|---|---|---|---|
| ២ | **ហានិភ័យទីផ្សារ** | តម្លៃទីផ្សារត្រីសាច់ធ្លាក់ចុះនឹងប៉ះពាល់ដល់ការផលិតកូនត្រី។ | - ចងក្រងបណ្តុំអ្នកផលិតកូនត្រី និងចិញ្ចឹមត្រីសាច់ដើម្បីភ្ជាប់ខ្សែច្រវាក់តម្លៃទីផ្សារ។ |

**៦-សេចក្តីសន្និដ្ឋាន÷**

តាមរយៈចុះជួបកសិករផ្ទាល់បានបង្ហាញថា÷ ត្រីឆ្ពិនជាប្រភេទត្រីដែលប្រជាពលរដ្ឋនៅតាមជនបទចូលចិត្តចិញ្ចឹមជាលក្ខណៈគ្រួសារ និងមានការបង្កាត់ភ្ញាស់ខ្នាតតូច ដោយសារបច្ចេកទេសនៃការបង្កាត់ភ្ញាស់ត្រីឆ្ពិនមានភាពសាមញ្ញងាយស្រួលជាងប្រភេទត្រីផ្សេងៗ ព្រមទាំងចំណាយដើមទុនតិចទៀតផង។ ត្រីឆ្ពិនត្រូវបានកសិករនិយមចិញ្ចឹមជាលក្ខណៈគ្រួសារ និងសម្រាប់ពិធីលែងកូនត្រីក្នុងទិវាមច្ឆជាតិឬទិវាធម្មជាតិផ្សេងៗជារៀងរាល់ឆ្នាំនៅតាមសហគមន៍។ ថ្លៃដើមផលិតកូនត្រីឆ្ពិនជាមធ្យម ៤៣.៧៤រៀល/កូន និងតម្លៃលក់ចន្លោះពី៨០-១២០រៀល/កូន អាចចំណេញជាមធ្យម ៥៦.២៦រៀល/កូន។ ប៉ុន្តែអត្រាបាត់បង់មិនត្រូវឱ្យលើសពី៣០% និងត្រូវបង្កាត់ភ្ញាស់យ៉ាងហោចណាស់ ១០០,០០០កូន/វគ្គ ទើបទទួលបានផលចំណេញ។

ផែនការអាជីវកម្មច្បាស់លាស់ជាកត្តាសំខាន់ក្នុងការគ្រប់គ្រងខ្សែច្រវាក់ផលិតកម្ម និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងបង្កឱ្យរាំងស្ទះដល់អាជីវកម្ម។ ទិសដៅផលិតកម្ម បច្ចេកទេស ធាតុចូលក្នុងដំណើរការផលិតកម្ម ទុនវិនិយោគ អតិថិជនគោលដៅ គួរត្រូវបានកំណត់ និងត្រៀមរួចរាល់មុនអាជីវកម្មចាប់ផ្តើម។

អ្នកផលិតកូនត្រីពូជ មិនត្រឹមតែយកចិត្តទុកដាក់ទៅលើបច្ចេកទេសផលិតកូនត្រីប៉ុណ្ណោះទេ ប៉ុន្តែត្រូវយកចិត្តទុកដាក់ផ្សព្វផ្សាយបច្ចេកទេសដល់អ្នកចិញ្ចឹមត្រីផងដែរ ដើម្បីឱ្យអ្នកចិញ្ចឹមត្រីទិញកូនត្រីយកទៅចិញ្ចឹមទទួលបានជោគជ័យ។ កសិករផលិតកូនត្រីត្រូវបង្កើតទំនាក់ទំនងល្អជាមួយកសិករចិញ្ចឹមត្រីទាំងក្នុង-ក្រៅខេត្ត និងអាជ្ញាធរមូលដ្ឋាន ដើម្បីផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី ជំរុញឱ្យកសិករចិញ្ចឹមត្រីមានការកើនឡើង៕

**ប្រភពសិក្សាស្រាវជ្រាវ÷**


- កសិដ្ឋានបង្កាត់ភ្ញាស់កូនត្រី នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង
- ឯកសារបច្ចេកទេសបង្កាត់ភ្ញាស់កូនត្រីឆ្ពិននៃគម្រោង FAIEX-JICA
- ឯកសារបច្ចេកទេសបង្កាត់ភ្ញាស់កូនត្រីឆ្ពិននៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- ឯកសារបច្ចេកទេសបង្កាត់ភ្ញាស់កូនត្រីឆ្ពិននៃសកលវិទ្យាល័យជលផលប្រទេសវៀតណាម